សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងឱកាសទិវាជនពិការកម្ពុជាលើកទី១៩ និងទិវាជនពិការអន្តរជាតិលើកទី៣៥ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៧

- *សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*
- *សម្តេច ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី*
- *បងប្អូននិងក្មួយៗជនពិការ ជនរួមជាតិ ជាទីស្នេហា!*

ក្នុងឱកាសដ៏មហោឡារិកនៃទិវាជនពិការកម្ពុជាលើកទី១៩ និងទិវាជនពិការអន្តរជាតិលើកទី៣៥ នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៧នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ សូមសម្តែងនូវការអបអរសាទរចំពោះការប្រារព្ធទិវាដ៏មានសារសំខាន់នេះ។ ការប្រារព្ធទិវានេះគឺជាការបង្ហាញអំពីឆន្ទៈនិងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សិទ្ធិ សេរីភាព និងសុខុមាលភាពជនពិការ ហើយជាការអំពាវនាវដល់បងប្អូនជនរួមជាតិយើងទាំងអស់ សូមជួយផ្តល់ការគាំទ្រដោយគ្មានការរើសអើង ចំពោះជនពិការដែលជាធនធានមិនអាចមើលរំលងបានក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។

ឆ្នាំ២០១៧នេះ ទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ ត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ **«ធ្វើឱ្យមានភាពរឹងមាំ ស្របនឹងសង្គមមួយមានសន្តិភាពសម្រាប់ទាំងអស់គ្នា»** ក្នុងគោលបំណងដើម្បីអបអរសាទរភាពជោគជ័យនៃវិស័យពិការភាពនៅកម្ពុជា ហើយបន្តបង្ហាញឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិ និងការចូលរួមរបស់ជនពិការ ធានាដល់ការធ្វើបរិយាប័ន្ន និងចលនាការនៃវិស័យពិការភាពដើម្បីទទួលបានស័ក្តិសិទ្ធិភាពនៃការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ «ធ្វើឱ្យសិទ្ធិក្លាយជាការពិត» ក៏ដូចជាផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨។

រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងវិស័យពិការភាព សំដៅជួយដល់ជនពិការ និងក្រុមគ្រួសារ ឱ្យទទួលបានគុណភាពជីវិតល្អប្រសើរ គ្មានការរើសអើង ទទួលបានសេវាសង្គមនិងសេវាសាធារណៈស្មើគ្នា ការចូលរួមគ្រប់សកម្មភាពក្នុងសង្គម ទាំងការទៅចុះឈ្មោះបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោត ការទទួលបានការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរ ព្រមទាំងការគិតគូរដាក់បញ្ចូលបញ្ហាពិការភាពក្នុងគ្រប់វិស័យ តាមរយៈការកែ

សម្រួលនិងរៀបចំលិខិតបទដ្ឋានគតិយុត្ត ការចុះផ្សព្វផ្សាយការយល់ដឹងអំពីវិស័យពិការភាពទៅគ្រប់ក្រសួង ស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍនានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ជនមានពិការភាពគ្រប់រូបនៅកម្ពុជា។

ទន្ទឹមនឹងនេះ សុខុមាលភាពរបស់ជនពិការ ក៏ត្រូវបានយកចិត្តទុកដាក់ពីគ្រប់មជ្ឈដ្ឋាន ស្របតាមកាលានុវត្តភាពនៃការអភិវឌ្ឍរីកចម្រើនរបស់ប្រទេសជាតិ។ ជនពិការ ត្រូវបានផ្តល់អាទិភាពក្នុងការជ្រើសរើសឱ្យចូលបម្រើការងារនៅក្នុងក្រសួង ស្ថាប័នរដ្ឋ ចំនួន៤៣ ស្ថាប័ន ដោយគិតក្នុងឆ្នាំ២០១៧នេះ មានជនពិការចូលបម្រើការងារសរុបចំនួន២,៧៣៧នាក់ ក្នុងនោះពិការកម្រិតធ្ងន់មានចំនួន ១,១៨០នាក់ ដែលក្នុងម្នាក់គិតស្មើនឹងចំនួន២នាក់ មានចំនួនសរុប ៣,៩១៧ នាក់ ស្មើនឹង ១.៧៨ ភាគរយ បច្ចុប្បន្នក្រសួង ស្ថាប័ននានា បាននិងកំពុងជ្រើសរើសឱ្យគ្រប់តាមអត្រាកំណត់ចំនួន ២ ភាគរយ នៅក្នុងឆ្នាំ២០១៨។

ជនពិការក្រីក្រនៅតាមសហគមន៍ ចំនួន ៣,៦១៧នាក់ និងកំពុងទទួលនូវផលប្រយោជន៍តាមរយៈការអនុវត្តការផ្តល់របបគោលនយោបាយ ដើម្បីចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិនានា ទាក់ទិននឹងការកាត់បន្ថយភាពក្រីក្រ។ ជាក់ស្តែងរាជរដ្ឋាភិបាលបានផ្តល់កម្មសិទ្ធិដីធ្លីនិងបានកសាងលំនៅឋានជូនជនពិការតាកែនកោះស្លា តំបន់អភិវឌ្ឍជនពិការខេត្តកំពត ៣១៧ នៅស្រុកគូលែន ខេត្តសៀមរាប និងនៅភ្នំឆ័ត្រ ខេត្តបន្ទាយមានជ័យ។ យើងក៏បានផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ និងគាំទ្រជនពិការចងក្រងក្រុមជួយខ្លួនឯង ចងក្រងអង្គការជនពិការថ្នាក់ឃុំ ស្រុក ខេត្ត ក្នុងទិសដៅឲ្យជនពិការអាចជួយគ្នាទៅវិញទៅមក រៀបចំផែនការក្នុងការដាក់បញ្ចូលវិស័យពិការភាពជាមួយអាជ្ញាធរមូលដ្ឋានថ្នាក់ឃុំ ស្រុក និងខេត្ត ជាពិសេសចូលរួមចំណែកជួយដល់ជនពិការក្រីក្រ ក្នុងការលើកកម្ពស់ជីវភាពរស់នៅប្រកបដោយឯករាជ្យស្មើភាព ស្មើសិទ្ធិ និងសេចក្តីថ្លៃថ្នូរ។ ហេតុមកដល់បច្ចុប្បន្នជនពិការបានចងក្រុមជួយខ្លួនឯងចំនួន១៩៥០ក្រុម អង្គការជនពិការ ចំនួន៧០ ជនពិការប្រមាណចំនួន ២៨,០០០នាក់ក្នុងមួយឆ្នាំ បានទទួលការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា និងជនពិការចំនួន ១៩២នាក់ បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈនិងមុខរបរ ក្នុងឆ្នាំ២០១៦។ ជនពិការក្រីក្រនៅតាមសហគមន៍ បាននិងកំពុងទទួលនូវផលប្រយោជន៍ជាច្រើនដូចជា ការពិនិត្យព្យាបាលនិងការថែទាំសុខភាព ការទទួលសេវាស្តារលទ្ធភាពពលកម្ម ថ្លៃអាហារហូបចុកសោហ៊ុយធ្វើដំណើរ ដោយបាននៅខេត្តប៉ៃលិន ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដើម្បីចូលរួមចំណែកអនុវត្តគោលនយោបាយជាតិគាំពារសង្គម ផែនការយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិនានា ដែលទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ។ យើងក៏បានរៀបចំបង្កើតឲ្យមានអក្សរស្ទាប និងភាសាសញ្ញាសម្រាប់ជនពិការភ្នែក និងមនុស្សគថ្លង់ ដោយបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៃវិស័យអប់រំ និងព័ត៌មានវិទ្យា ព្រមទាំងបានបកប្រែជាភាសាសញ្ញានៅតាមស្ថានីយ៍ទូរទស្សន៍នានា ដើម្បីផ្តល់ឱកាសឲ្យជនពិការទទួលបានព័ត៌មានយ៉ាងទូលំទូលាយ។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១១៧ អនក្រ បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិអប់រំពិសេស ដើម្បីបណ្តុះបណ្តាលគ្រូថ្នាក់អប់រំពិសេសសម្រាប់ជាប្រយោជន៍ដល់សិស្សមានពិការភាព។ ជាមួយគ្នានេះដែរ កុមារពិការក៏ទទួលបានការសិក្សានៅតាមគ្រឹះស្ថានសាធារណៈនិងឯកជនទូទាំងប្រទេស ដូចកុមារដទៃ ដោយស្មើភាព និងមិនមានការរើសអើង ក្នុងនោះកុមារពិការនៅកម្រិតមត្តេយ្យសិក្សាមានចំនួន ៣,១២៣នាក់ កម្រិតបឋមសិក្សា ៤៤,៣៨៧នាក់ កម្រិតមធ្យមសិក្សា ៦,៧១៧នាក់ សរុបទាំងអស់ ៥៤,២២៧នាក់។

អគារសិក្សាមួយចំនួនបានរៀបចំឲ្យមានជម្រាលសម្រាប់សិស្សពិការ មជ្ឈមណ្ឌលនិងសាលាសម្រាប់កុមារពិការភ្នែក និងគថ្លង់ ក៏ត្រូវបានអភិវឌ្ឍ ដើម្បីឲ្យកុមារពិការភ្នែក គថ្លង់ សតិបញ្ញា និងពិការផ្សេងៗទៀត ឲ្យមានឱកាសសិក្សាអប់រំរហូតដល់កម្រិតឧត្តមសិក្សា។ យុវជនពិការក៏ត្រូវបានលើកទឹកចិត្តឲ្យទៅប្រកួតប្រជែងជាសាកល និងមានគោលការណ៍ផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំពោះជ័យលាភីជនពិការ។ បច្ចុប្បន្ននេះ ជនពិការមួយចំនួនបានក្លាយជាបុគ្គលិកធ្វើមប្រកបដោយសមត្ថភាព ហើយគ្រូស្ម័គ្រចិត្តបង្រៀនជនពិការ និងជនពិការក៏ត្រូវបានលើកទឹកចិត្តផ្តល់អាទិភាពឱ្យចូលបម្រើការងារនៅស្ថាប័នរដ្ឋ។

ដោយឡែក កាកបាទក្រហមកម្ពុជា ក៏បានផ្តល់អំណោយមនុស្សធម៌ជាថវិកាដ៏ថ្លៃថ្លា និងសម្ភារៈជាច្រើនសន្ធឹកសន្ធាប់ ដើម្បីទ្រទ្រង់សកម្មភាពរបស់សមាគម អង្គការជនពិការនានា តួយ៉ាងដូចជា ការជួយឧបត្ថម្ភកសាងអគារស្នាក់នៅរបស់សមាគមសំនៀងតន្ត្រីជនពិការ និងបានធ្វើសកម្មភាពមនុស្សធម៌ជាច្រើនទៀត ដើម្បីជួយដល់ចាស់ជរា ស្ត្រីមេម៉ាយ កុមារកំព្រា ជនអនាថា អ្នកផ្ទុកមេរោគអេដស៍ និងជនងាយរងគ្រោះផ្សេងៗទៀត ជាពិសេសជនពិការក្រីក្រ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការទាំងអស់នៃក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័ននានា អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងមូលនិធិជនពិការ ជាពិសេសបងប្អូនជនពិការដែលបានចូលរួមចំណែកយ៉ាងសកម្ម និងជំរុញឲ្យមានការដាក់បញ្ចូលជនពិការក្នុងការអភិវឌ្ឍ។

ក្នុងស្មារតីនេះ ដើម្បីចូលរួមចំណែកគាំទ្រទិវាជនពិការកម្ពុជាលើកទី១៩ និងទិវាជនពិការអន្តរជាតិលើកទី៣៥ ឆ្នាំ២០១៧នេះ ខ្ញុំព្រះករុណាខ្ញុំ សូមធ្វើការអំពាវនាវដូចតទៅ៖

*ទី១-* គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំការបង្កលក្ខណៈងាយស្រួលចេញចូលទីកន្លែងសាធារណៈសម្រាប់ជនពិការគ្រប់ប្រភេទ ដូចជា៖ ការរៀបចំចំណតយានយន្តពិសេសសម្រាប់ជនពិការ ការធ្វើជម្រាល ការបំពាក់ឧបករណ៍ធ្នាក់ដៃ ទ្វារ បន្ទប់ទឹកជនពិការ ការដាក់ស្លាកសញ្ញានានា នៅតាមក្រសួង ស្ថាប័ន មន្ទីរ ផ្លូវថ្នល់ ទីកន្លែងលំហែកាយ មជ្ឈមណ្ឌលវប្បធម៌ កន្លែងលេងកីឡា កន្លែងកម្សាន្ត គ្រឹះស្ថានអប់រំ សណ្ឋាគារ មន្ទីរពេទ្យ មណ្ឌលសុខភាព និងមធ្យោបាយដឹកជញ្ជូន ។ល។

*ទី២-* គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវចាត់អាទិភាពដាក់បញ្ចូលការងារពិការភាព និងកញ្ចប់ថវិកានៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ក្នុងទិសដៅសម្រេចឱ្យខាងតែបាននូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ មុំទី៣ ការងារអាទិភាពទី៤ របស់រាជរដ្ឋាភិបាល ក៏ដូចជាផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨។

*ទី៣-* ត្រូវបន្តជំរុញនិងយកចិត្តទុកដាក់គិតគូរអំពីផលប្រយោជន៍ និងលើកតម្កើងជីវភាពរស់នៅរបស់បងប្អូនជនពិការឲ្យបានសមរម្យស្របតាមសេដ្ឋកិច្ចជាតិ និងត្រូវមានវិធានការណ៍ចាំបាច់នានា ដើម្បីបំផុសលើកទឹកចិត្តពលរដ្ឋ សប្បុរសជន ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលនានា ឲ្យចូលរួមឧបត្ថម្ភជនពិការ ព្រមទាំងត្រូវលើកទឹកចិត្តដល់ជនដែលមានពិការភាពដែលប្រកបមុខរបរ អាជីវកម្ម សិប្បកម្មជាលក្ខណៈឯកត្តជន ឬគ្រួសារ ឬសមូហភាពរបស់ជនពិការ តាមរយៈការកាត់បន្ថយពន្ធ និងការផ្តល់អាទិភាពផ្សេងៗស្របតាមច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ។

ទី៤- គ្រប់ក្រសួង ស្ថាប័នរដ្ឋ វិស័យឯកជន និងសង្គមស៊ីវិលធ្វើការលើវិស័យពិការភាព ត្រូវរួមគ្នាអនុវត្តរបបគោលនយោបាយជាតិសន្តិសុខសង្គមដើម្បីលើកកម្ពស់សុខុមាលភាពជនពិការ។

*ទី៥-* គ្រប់ក្រសួង ស្ថាប័នរដ្ឋ ត្រូវលើកទឹកចិត្តជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញមុខងារតួនាទីទទួលខុសត្រូវក្នុងមុខតំណែង ឲ្យមានសិទ្ធិចូលបម្រើការងារដោយគ្មានការរើសអើង រាប់ទាំងការបម្រើការងារជាមន្ត្រីរាជការ កម្មករ និយោជិត កូនជាង ឬកម្មសិក្សាការីជាដើម។

*ទី៦-* ត្រូវបន្តលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន រោងចក្រ សហគ្រាស សណ្ឋាគារ ភោជនីយដ្ឋាន និងគ្រឹះស្ថានទាំងអស់ក្នុងការជ្រើសរើសជនពិការ ដោយការភ្ជាប់លើកអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ។

*ទី៧-* ក្រុមប្រឹក្សាសកម្មភាពជនពិការ ត្រូវបន្តដឹកនាំចាត់ចែង អនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងជំរុញការអនុវត្តលិខិតបទដ្ឋានអន្តរជាតិពាក់ព័ន្ធពិការភាពជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ឲ្យដំណើរការទៅបានដោយរលូននិងប្រកបដោយប្រសិទ្ធភាព ព្រមទាំងត្រូវធ្វើរបាយការណ៍ដាក់ជូនរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ។

*ទី៨-* ក្រសួងព័ត៌មាន ត្រូវធ្វើការណែនាំដល់គ្រប់ការណែនគ្រប់ស្ថានីយវិទ្យុនិងទូរទស្សន៍របស់រដ្ឋ និងឯកជន ព្រមទាំងគ្រប់ប្រព័ន្ធសារព័ត៌មាន សូមបន្តជួយផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវការយកចិត្តទុកដាក់ និងលើកកម្ពស់សុខុមាលភាពជនពិការនៅកម្ពុជា ជាពិសេសត្រូវមានការបកប្រែជាភាសាសញ្ញា និងអក្សររត់នៅតាមបណ្តាស្ថានីយទូរទស្សន៍ ដើម្បីសម្រួលដល់ជនពិការក្នុងការទទួលបានព័ត៌មានផ្សេងៗ។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមប្រគេនពរសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេច ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី បងប្អូន ក្មួយៗ ជនពិការ និងជនរួមជាតិទាំងអស់ សូមប្រកបបាននូវពុទ្ធពរប្រាំប្រការ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៧

**ហ៊ុន សែន**